00800235



ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 12 / 04 / 2012
ម៉ោង (Time/Heure): 13:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

**សាធារណៈ**

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ អង្គារ ទី ២៧ ខែ មីនា ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្តី - ថ្ងៃទី ៤២

រៀបចំដោយ: ដាវ អានសាន និង Matteo CRIPPA

---

| |
|---|
| **កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ** |
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី និង ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោក ដាវ អានសាន, លោក Matteo CRIPPA, លោកស្រី Natacha Wexels-Riser, លោក ឌុច ផារី |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក សេង ប៊ុនឃាង, លោក William SMITH , លោក Dale LYSAK, លោក ពេជ្រ សម្បត្តិ, លោក តូច វណ្ណារិទ្ធ, លោក ប៊ូ ចាន់ថន, លោក ប៉ាក់ ចាន់លីណូ, លោកស្រី Sarah ANDREWS (វត្តមានពេលព្រឹក)។ |

| |
|---|
| ជនជាប់ចោទ៖ អៀង សារី, នួន ជា, ខៀវ សំផន |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Michiel PESTMAN, លោក Jasper PAUW, លោក ព្រំ ផល្លា។ |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael KARNAVAS, លោក សូ មូស្សេនី ។ |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, និងលោក Arthur VERCKEN, Ms. Marie CAPOTORTO។ |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ្រ អង្គ, លោកស្រី Elisabeth SIMONNEAU-FORT, លោកស្រី ទី ស្រីនណា, លោកស្រី Lyma NGUYEN, លោក ឡោ ជុនធី, លោកស្រី ម៉ុច សុវណ្ណារី, លោក វ៉េន ពៅ, លោក Barnabé NEKUIE , លោកស្រី ស៊ិន សូវន។ |
| សាក្សី៖ កាំង ហ្កេចអ៊ាវ ហៅ ឌុច (TCW-281) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ, លោក ឡាយ ណារ៉ា, លោក មៀច សុវណ្ណា, លោក នូ មូណូវ័ត្ត, លោកស្រី Seynabou DIOP។ |
| ផ្សេងៗ៖ កញ្ញា Alexandra PRASSOLOFF |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃអង្គារ ទី ២៧ ខែ មីនា ឆ្នាំ ២០១២ | ចាប់ផ្តើមម៉ោង៖ ៩.០៥ | បញ្ចប់ម៉ោង៖ ១៦.00 (៦ម៉៥៥នាទី) |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៣០ | បញ្ចប់ម៉ោង៖ ១០.៥៥ (២០នាទី) |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១២.00 | បញ្ចប់ម៉ោង៖ ១៣.៣០ (១ម៉៣០នាទី) |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៤០ | បញ្ចប់ម៉ោង៖ ១៥.00 (២០នាទី) |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ | | ៤ ម៉ោង ៤០នាទី |

**កិច្ចដំណើរការនីតិវិធី៖**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការបន្តសួរសាក្សី កាំង ហ្កេចអ៊ាវ | តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ | ៩.០៥ | ១៦.00 |

| | | | |
|---|---|---|---|
| សំណើលះបង់សិទ្ធិក្នុងការចូលរួម សវនាការដោយផ្ទាល់ | មេធាវី អៀង សារី<br>មេធាវី នួន ជា | ១០.៣០<br>១២.០០ | ១០.៣០<br>១២.០០ |
| ការជំទាស់លើការលើកសំណួរចំពោះ សាក្សី កាំង ហ្កេកអ៊ាវ | មេធាវី នួន ជា<br><br>មេធាវី អៀង សារី | ១០.០០<br>១៣.៤៥<br>១៤.៣០ | ១០.០០<br>១៣.៥០<br>១៤.៣៥ |
| ការជំទាស់ និងវែកញែកលើការសួរ និង លើសក្ខីកម្មរបស់សាក្សី | មេធាវី នួន ជា<br>មេធាវី អៀង សារី<br>មេធាវី ខៀវ សំផន | ១១.២០<br>១៤.៣០<br>១៥.៣០ | ១១.៤០<br>១៤.៣៥<br>១៥.៥០ |

**សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

ប្រធានអង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការ និង ឲ្យនាំសាក្សីចូលក្នុងបន្ទប់សវនាការ។

**ការបន្តសួរសាក្សី កាំង ហ្កេកអ៊ាវ**

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិបន្តសួរសាក្សី កាំង ហ្កេកអ៊ាវ ដោយចាប់ផ្ដើមអំពីការបង្ហាញឯកសារមួយចំនួនទៅសាក្សី និងសួរសំណួរពាក់ព័ន្ធនឹងឯកសារទាំងនោះ។

**ការលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់**

មេធាវីការពារក្ដី អៀង សារី និង នួន ជា ស្នើសុំលះបង់សិទ្ធិឲ្យកូនក្ដីរបស់ខ្លួន ក្នុងការចូលរួមសវនាការដោយផ្ទាល់ ប៉ុន្តែសុំចូលរួមសវនាការពីបន្ទប់រង់ចាំខាងក្រោមបន្ទប់សវនាការ។ អង្គជំនុំជម្រះអនុញ្ញាតតាមសំណើមេធាវីការពារក្ដី អៀង សារី (ម៉ោង ១០.៣០ នាទី) និងមេធាវីការពារក្ដី នួន ជា (ម៉ោង ១២.០០) ដោយបង្គាប់ឲ្យមេធាវីការពារក្ដីប្រគល់លិខិតលះបង់សិទ្ធិជាលាយលក្ខណ៍អក្សរជូនអង្គជំនុំជម្រះ។ ក្រុមការពារក្ដី អៀង សារី និងក្រុមការពារក្ដី នួន ជា បានផ្ដល់លិខិតលះបង់សិទ្ធិដល់ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង។

**ការជំទាស់លើការតាំងសំណួរចំពោះសាក្សី កាំង ហ្កេកអ៊ាវ**

មេធាវី នួន ជា លើកឡើងពីការសួរសំណួរនាំមុខរបស់សហព្រះរាជអាជ្ញា (ម៉ោង១០), ការចាត់ទុកសាក្សីរូបនេះជាអ្នកជំនាញ តាមរបៀបសួរឲ្យសាក្សីនេះបកស្រាយ (ម៉ោង១៣.៤៥) ចំពោះសាក្សី។ មេធាវី អៀង សារី (ម៉ោង១៤.៣៥) ក៏បានលើកឡើងពីការសួរសំណួរនាំមុខរបស់សហព្រះរាជអាជ្ញា។ អង្គជំនុំជម្រះរំលឹកដល់សហព្រះរាជអាជ្ញាថា សំណួរចំពោះសាក្សីមិនត្រូវមានលក្ខណៈជាសំណួរនាំមុខឡើយ។

**ការជំទាស់លើសក្ខីកម្មរបស់សាក្សី**

ក្រុមមេធាវីជនជាប់ចោទ លើកឡើងថា សំណួររបស់សហព្រះរាជអាជ្ញានៅក្រៅវិសាលភាពនៃសវនាការ និងសក្ខីកម្មរបស់សាក្សីនៅដំណាក់កាលនេះមិនគប្បីអំពីមន្ទីរ ស-២១។ ក្រុមមេធាវី ខៀវ សំផន បានជំទាស់លើឯកសារមួយចំនួនដែលបង្ហាញដល់សាក្សី ដោយសំអាងថា សាក្សីមិនបានដឹងពីឯកសារទាំងនេះនៅអំឡុងកម្ពុជាប្រជាធិបតេយ្យ អង្គជំនុំជម្រះរំលឹកអំពីការសម្រេចរបស់ខ្លួនកន្លងមក ដោយបញ្ជាក់ថា ភាគីអាចបង្ហាញឯកសារមួយដល់សាក្សី ហើយសួរសាក្សីនោះជាមុនថាតើបានឃើញឯកសារនេះពីមុនមកឬទេ។ ប្រសិនបើសាក្សីមិនធ្លាប់បានឃើញពីមុនមកទេ ឯកសារនោះមិនត្រូវបង្ហាញដល់សាក្សីឡើយ។ អង្គជំនុំជម្រះសម្រេចសំណើជំទាស់របស់មេធាវី គ្មានប្រសិទ្ធភាព និងបញ្ជាក់ថា ឯកសារដែលបង្ហាញដល់សាក្សីមិនចាំបាច់តែជាឯកសារដែលសាក្សីស្គាល់ដឹងឮនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះទេ។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង**

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/1532 | 3.1 | 00068149-00068149 00235659-00235659 00623527-00623527 | ប្រវត្តិរូបអ្នកទោសឈ្មោះ អ៊ឹង សុក ជាប្រធានពាណិជ្ជកម្ម ប្រចាំនៅហុងកុង<br>Biography of Prisoner, Ing Sok, Trade Chief in Hong Kong<br>Biography of Prisoner, Ing Sok, Trade Chief in Hong Kong | P | | | |
| E3/1533 | 3.5 | 00068148-00068148, P 00000039-00000043 00242035-00242035 00598003-00598003 | ប្រវត្តិរូបអ្នកទោសជាប់ឃុំឃាំងឈ្មោះ ផល វ៉ា, សមាជិកគណកម្មាធិការពាណិជ្ជកម្មរដ្ឋប្រចាំនៅហុងកុង<br>Prisoner biography of Phal Va, Committee member of Commercial state in Hong Kong.<br>Prisoner biography of Phal Va, Committee member of Commercial state in Hong Kong. | P | | | |
| E3/1534 | D108/26.82 | 00087007-00087009 00181667-00181669 | បញ្ជីឈ្មោះអ្នកទោសផ្នែកក្រសួងការបរទេស<br>Annex 82: S-21 Prisoner List containing names of prisoners from the Ministry of Foreign Affairs | P | | | |
| E3/1535 | 16.80 | 00021088-00021089 00183657-00183662 | ឈ្មោះអ្នកទោសផ្នែក ពេទ្យអង្គការ<br>Name of prisoners of Angkar Hospital Section | P | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/1536 | D121.4 | 00021088-00021089 00183657-00183662 | ឧបសម្ព័ន្ធ៤ : បញ្ជីអ្នកទោស ស២១០: ពេទ្យអង្គការ ERN 00021088<br>Annex 4: S21 Prisonners List: Angkar Hospital, ERN 00021088 | P | | | |
| E3/1537 | D43/IV-Annex 75 | 00174754-00174760 00224639-00224639 00271459-00271459 | ឧបសម្ព័ន្ធ ៧៥៖ ៦៤២bbkkh សម្រង់ចម្លើយសារភាពរបស់ ទីវ ម៉ី ហៅ សន្តិភាព<br>Annex 75: 642bbkkh Colour copy Excerpt of Confession of Tiv Mei alias Santepheap<br>Annexe 75: 642bbkkh l'extrait en copie couleur de la confession de Tiv Mei alias Santepheap | P | | | |
| E3/1538 | D312.1.46 | 00090136-00090137 | បញ្ជីឈ្មោះអ្នកទោសដែលត្រូវកំទេចហើយនៅថ្ងៃទី ២២ មិនា ៧៦ | P | | | |
| E3/1539 | 7.2 | 00006744-00006747 00182892-00182903 | ឈ្មោះអ្នកទោសដែលងាប់នៅមន្ទីរ ស-២១<br>Name list of prisoners has been died at S-21 Office | P | | | |
| E3/1540 | D312.1.55 | 00090138-00090141 | ឈ្មោះអ្នកទោសដែលងាប់នៅមន្ទីរ ស-២១ | P | | | |
| E3/1541 | 16.46 | 00040750-00040756, 00106309-00106315 00233891-00233898, 00185348-00185363 00296018-00296018 | ស្ថិតិអ្នកទោសដែលផ្អាកសួរក្នុងខែមករា ១៩៧៧<br>Statistique of prisoners interrupted to interrogate in January 1977<br>Liste de la désignation de zone Nord en 1963-1977 | P | | | |
| E3/1542 | D312.1.25 | 00008118-00008142 | ស-២១ បញ្ជីរាយឈ្មោះអ្នកទោសដែលកំពុងសួរក្នុងខែ ១,៧៧ | P | | | |
| E3/727 | 11.14 | 00064551-00064585 00185322-00185347 00524447-00524475 | ទង់បដិវត្ត លេខពិសេស ឧសភា មិថុនា ១៩៧៨<br>Tung Pakdevath No. 8 August, 1978<br>Tung Pakdevath No. 8 August, 1978 | P | | | |
| E3/833 | 14.3 | 00077661-00078056 00242259-00242263, 00184579-00184618 00373110-00373115, 00282468-00282547 | កំណត់ហេតុរបស់ចាន់ជាភាសាខ្មែរចុះថ្ងៃទី១៧ធ្នូ១៩៧៧ S-21 Notebook by MAM Nai alias Chan [Corrigé 1]<br>S-21 Livre de Mam Nai alias Chan | P | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/1543 | D159/5.22 | 00299584-00299956 | ចម្លើយសារភាព ចាប ម៉ិត លេខាស្រុក ខ្សាច់កណ្ដាល តំបន់២២ ភូមិភាពបូព៌ា | P | | | |
| E3/1544 | 10.5 | 00053000-00053000 00184020-00184020 00290166-00290166 | វិធានការសួរចម្លើយដែលធ្វើឱ្យ ប៉ែន សាន ហៅ យ៉ា សារភាពនៅថ្ងៃទី ២៦ កញ្ញា ៧៦<br>Interrogating measure that Pen San call Ya gaven the trusth on 26/9/76<br>Les moyens d'interroger Pen San alias Ya, à passer aux aveux le 26/9/76 | P | | | |
| E3/1177 | D366/7.1.481 | 00002251-00002251 00517314-00517314 00501189-00501189 | សំបុត្ររបស់ឌុច ជូនចំពោះសមមិត្ត ប៉ុន<br>Duch's letter to Comrade Pon Duch's letter to Comrade Pon | P | | | |
| E3/259 | 9.2 | 00089841-00089852 00184833-00184839 S 00012644-00012659 | សំណុំឯកសារច្បាប់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យមានចំណង រដ្ឋធម្មនុញ្ញនៃកម្ពុជាប្រជាធិបតេយ្យ<br>DK Government Legal Documents entitled<br>Constitution of Democratic Kampuchea<br>Swedish Collection Document 1976 | P | | | |
| E3/214 | 9.1 | 00053007-00053080 00184022-00184047 00292914-00292934 | លក្ខន្តិកៈបក្សកុម្មុយនិស្តកម្ពុជា<br>Statute of cambodiancommunist party<br>Status du Parti Communiste du Kampuchéa | P | | | |
| E3/12 | 6.3 | 00003136-00003142, 00000758-00000764 00182809-00182814 00224363-00224367 | សេចក្ដីសំរេចរបស់គណៈមជ្ឈឹមអំពីបញ្ហាផ្សេងៗមួយចំនួន<br>Decision of central committee on a number of problems<br>Decision of central committee on a number of problems | P | | | |

<u>**ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖**</u>

- អង្គជំនុំជម្រះសម្រេចអនុញ្ញាតឱ្យជនជាប់ចោទ អៀង សារី និង នួន ជា ចូលរួមដំណើរការសវនាការពីបន្ទប់នៅខាងក្រោមសាលសវនាការ និងបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់រង់ចាំ និងបង្គាប់ឱ្យមេធាវីផ្ដល់លិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់របស់ជនជាប់ចោទ។
- អង្គជំនុំជម្រះបញ្ជាក់អំពីសេចក្ដីសម្រេចរបស់ខ្លួនថា ឯកសារដែលបង្ហាញ ដល់សាក្សីមិនចាំបាច់តែជាឯកសារដែលសាក្សីស្គាល់ដឹងឮនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះ ទេ។

- បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ អៀង សារី នួន ជា ខៀវ សំផន និងសាក្សី កាំង ហ្គេកអ៊ាវ ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទ និងសាក្សីត្រឡប់មកកាន់បន្ទប់សវនាការវិញឲ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២។

| **កាលបរិច្ឆេទបន្តសវនាការ៖** |
| --- |
| សវនាការនឹងបន្តនៅថ្ងៃ ពុធ ទី ២៨ ខែ មីនា ឆ្នាំ ២០១២ វេលាម៉ោង ០៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១២

ក្រឡាបញ្ជី ក្រឡាបញ្ជី

**ជាវ អានសាន** Matteo CRIPPA